# អ្នកទោសគុកទួលស្លែង ត្រូវបានដោះលែងដើម្បីឱ្យមកគូរនិងឆ្លាក់រូបរបស់ ប៉ុល ពត

***ដោយ ឡូរ៉ា ម៉ាក់ដូណល់***

***ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩***

*ប្រែសម្រួលដោយ ខែន សុខស្រីនិត*

*ថ្ងៃនេះ អ្នកតាមដានដំណើរការអង្គជំនុំជម្រះជាង៥០០នាក់ រួមទាំងអ្នកភូមិមកពីខេត្តកណ្តាល រាប់រយនាក់បានប្រមូលផ្តុំគ្នានៅក្នុងសាលសវនាការដើម្បីស្តាប់សក្ខីកម្មរបស់ វ៉ាន់ ណាត ដែលជាអ្នករស់រានមានជីវិតពីគុកទួលស្លែង ឬមន្ទីរស-២១ ។*

*ក្នុងរយៈពេលធ្វើសក្ខីកម្មជាងបួនម៉ោង រឿងរ៉ាវដ៏មានឥទ្ធិពលមួយបានលាតត្រដាងពីជីវិតរបស់ជាងគំនូរម្នាក់មកពីខេត្តបាត់ដំបង ដែលទទួលរងនូវរឿងអកុសលអស់រយៈពេលមួយឆ្នាំនៅមន្ទីរស-២១ ហើយវិចិត្រកររូបនេះបានរួចរស់មានជីវិតដោយសារតែ ប៉ុល ពត ចង់បានរូបគំនូរនិងចម្លាក់ជារូបរបស់ខ្លួន។ វ៉ាន់ ណាត អាយុ៦៣ឆ្នាំ ដែលស្ថិតក្នុងស្ថានភាពសុខភាពទ្រុឌទ្រោមមានភាពស្ងប់ស្ងាត់និងមិនរំដើបរំជួលចិត្តក្នុងអំឡុងពេលធ្វើសក្ខីកម្មឡើយ ។ វ៉ាន់ ណាត បានរៀបរាប់ពីវត្តវិស័យរបស់អង្គជំនុំជម្រះ ពីព្រោះថា គាត់បានអធិប្បាយពីព័ត៌មានលម្អិតទាក់ទិននឹងបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ ប៉ុន្តែគាត់មិនបានធ្វើការសន្និដ្ឋានលើបញ្ហាដែលគាត់មិនបានឃើញឬដឹងដោយផ្ទាល់ឡើយ ។ វ៉ាន់ ណាត ហាក់បីដូច ជាមិនហ៊ានមើលទៅកាន់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ (ហៅ ឌុច) ដែលជាប្រធានមន្ទីរស-២១ទេ ។ ប៉ុន្តែ ឌុច ដូចជាមើលមកកាន់ វ៉ាន់ ណាត មិនដាក់ភ្នែកសោះ ។*

## ឌុច : «ទុកដើម្បីប្រើប្រាស់»

*ថ្ងៃទី១៧ ខែមេសា ឆ្នា១៩៧៥ នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានឡើងកាន់កាប់អំណាច វ៉ាន់ ណាត និងគ្រួសាររបស់គាត់ត្រូវបានបង្ខំឲ្យរស់នៅក្នុងសហករណ៍មួយជាមួយនឹងផ្ទះខ្ទមដ៏តូច និងម្ហូបអាហារបន្តិចបន្តួច ។ ស្របពេលជាមួយគ្នានេះ វ៉ាន់ ណាត និងក្រុមគ្រួសារត្រូវតែធ្វើស្រែឥតឈប់ឈរ ។ ការចាប់ខ្លួននៅក្នុងសហករណ៍តែងតែកើតមានឡើងជាប្រចាំ ហើយក្នុងឆ្នាំ១៩៧៧ វ៉ាន់*

ណាត បានក្លាយខ្លួនជាជនរងគ្រោះដែលត្រូវបានចាប់ខ្លួន ។ ដោយមិនបានដឹងពីមូលហេតុអ្វីសោះ វ៉ាន់ ណាត ត្រូវបានបញ្ជូនទៅឃុំខ្លួននៅក្នុងគុកភូមិភាគរបស់អង្គភាពបក្សកុម្មុយនីស្តកម្ពុជា ដែលគាត់ត្រូវបានសួរចម្លើយនិងធ្វើទារុណកម្មដោយឆក់ខ្សែភ្លើង ។ អ្នកសួរចម្លើយបានអះអាងថា ប៉ុល ពត មិនដែលចាប់មនុស្សខុសឡើយ ដូច្នេះ វ៉ាន់ ណាត ត្រូវតែសារភាពពីការប្រព្រឹត្តបទល្មើសក្លែងក្លាយ និងប្រាប់ឈ្មោះអ្នកដទៃទៀតដែលរស់នៅក្នុងសហករណ៍ជាមួយគាត់ដើម្បីរស់ ។ «ពាក់កណ្តាលរស់» និងដឹងខ្លួនតិចៗ វ៉ាន់ ណាត និយាយថា គាត់សូមសារភាពទោសកំហុសរបស់គាត់ ។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៨ វ៉ាន់ ណាត ត្រូវបានវាយខ្នោះដាក់ច្រវ៉ាក់ជើង និងបញ្ជូនតាមឡានមកកាន់កន្លែងមួយដែលក្រោយមកគាត់បានដឹងថាជាមន្ទីរស-២១ ។ បន្ទាប់ពីការមកដល់មន្ទីរស-២១ គាត់ត្រូវដោះសម្លៀកបំពាក់ឲ្យនៅសល់តែខោខ្លី ហើយត្រូវបានយាមល្បាតដោយអ្នកយាមគុក ។ ក្រោយមកទៀត គាត់ត្រូវគេចង-កនឹងខ្សែរួចបណ្តើរទាំងចងបិទភ្នែកជាមួយនឹងអ្នកទោសមួយក្រុម ដែលត្រូវចង-កភ្ជាប់គ្នាដើម្បីទៅថតរូប ។ វ៉ាន់ ណាត ត្រូវបាននាំទៅបន្ទប់ឃុំឃាំងរួមនៅជាន់ទីពីរ ។ នៅទីនោះ គាត់ត្រូវជាប់ច្រវ៉ាក់ជាជួរជាមួយនឹងអ្នកទោសម្ភៃទៅសាមសិបនាក់ផ្សេងទៀត ។ គាត់បានចំណាយពេលមួយខែនៅក្នុងបន្ទប់ឃុំឃាំងនេះ ដោយដេកនៅលើឥដ្ឋជាមួយនឹងអ្នកទោសប្រមាណសែសិបនាក់ទៅហុកសិបប្រាំនាក់ ។ ទាក់ទិននឹងលក្ខខណ្ឌរស់នៅវិញ វ៉ាន់ ណាត បាននិយាយថា «ខ្មែរក្រហមបន្ទាបបន្ថោកពួកយើងដែលជាអ្នកទោស ។ វាពិតជាពិបាកនិយាយណាស់» ។ អ្នកទោសទាំងអស់ទទួលបានបបរបីស្លាបព្រាកាហ្វេចំនួនពីរដងក្នុងមួយថ្ងៃតែប៉ុណ្ណោះ ។ ប្រសិនបើមានសត្វល្អិតធ្លាក់ពីលើពិដានអាគារវិញ អ្នកទោសនឹងវាយដណ្តើមគ្នាដោយសារតែភាពស្រេកឃ្លាន ។ យ៉ាងណាមិញ ប្រសិនបើអ្នកយាមគុកតាមទាន់អ្នកទោសទាំងនោះត្រូវទទួលរងនូវការវាយធ្វើបាប ។ អ្នកទោសត្រូវតែបន្ទោរបង់នៅនឹងកន្លែង ហើយត្រូវបានបាញ់ទឹកសម្អាតខ្លួននឹងបំពង់ទុយយ៉ូម្តងម្កាលប៉ុណ្ណោះ ។ អ្នកទោសបានកើតរមាស់ពេញនៅលើស្បែកទាំងអស់ ។ លើសពីនេះ អ្នកទោសទាំងអស់មិនអនុញ្ញាតឲ្យនិយាយ ធ្វើចលនា ឬអង្គុយដោយគ្មានការអនុញ្ញាតឡើយ ។ វ៉ាន់ ណាត បានបន្ថែមទៀតថា «ការស្លាប់តែងតែកើតឡើងយ៉ាងឆាប់រហ័ស» ។ «មនុស្សស្លាប់ម្នាក់ហើយម្នាក់ទៀត» ហើយសាកសពអ្នកទោសដែលស្លាប់នៅតែជាប់ច្រវ៉ាក់ជាមួយនឹងអ្នកទោសផ្សេងទៀតអស់មួយរយៈពេលមុននឹងយកទៅកប់ចោល ។

នៅថ្ងៃមួយ វ៉ាន់ ណាត ត្រូវបានហៅឲ្យមកជាន់ក្រោម ។ ស្ត្រីម្នាក់ដែលកំពុងតែត្រូវបាននាំខ្លួនដូចគាត់ដែរនោះបានរត់រួច ហើយលោតសម្លាប់ខ្លួនពីលើអាគារតែម្តង ។ ក្រោយពីហេតុការណ៍នេះមក ការប្រុងប្រយ័ត្នជាមុនត្រូវបានធ្វើឡើងដើម្បីការពារការធ្វើអត្តឃាតដូចជា ដកហូតខ្សែយឺតចេញពីខោខ្លី

ដើម្បីកុំឲ្យអ្នកទោសរឹតកសម្លាប់ខ្លួនជាដើម ។ ប៉ុន្តែការប្រុងប្រយ័ត្នជាមុននេះ មិនទទួលបានជោគជ័យទាំងស្រុងនោះទេ ។ នៅពេលមកដល់ជាន់ក្រោម វ៉ាន់ ណាត បានជួបទល់មុខគ្នាជាមួយនឹង ឌុច ។ ឌុចបានតម្រូវឲ្យ វ៉ាន់ ណាត រៀបរាប់ពីសមត្ថភាពគូររូបរបស់គាត់ ។ វ៉ាន់ ណាត ត្រូវបានបញ្ជាឲ្យទៅរស់នៅមូលដ្ឋានថ្មីនៅជាន់ជាប់ដីនៅក្នុងរោងជាងមួយ ជាមួយនឹងអ្នកទោសផ្សេងទៀតដូចជា ជាងដែកជាងជួសជុលម៉ាស៊ីន និងជាងគំនូរផ្សេងទៀត ។ នៅក្នុងស្ថានភាពថ្មីនេះ វ៉ាន់ ណាត ទទួលបានរបបអាហារប្រសើរជាងមុន ហើយគាត់ត្រូវបានអនុញ្ញាតឲ្យផ្ញូតទឹក ពាក់ខោអាវ និងធ្វើចលនាដោយសេរីនៅក្នុងរោងជាង ។ គាត់បានចំណាយពេលដប់មួយខែនៅក្នុងរោងជាងនោះ ដើម្បីគូររូបបុរសម្នាក់ដែលក្រោយមកគាត់ដឹងថាជា ប៉ុល ពត ។ គាត់ក៏បានគូររូបមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀតនិងរូបភាពខ្លះៗស្តីពីកងទ័ពវៀតណាមដែលត្រូវបានវាយធ្វើបាបផងដែរ ។ ប៉ុន្មានឆ្នាំក្រោយពីការដោះលែង វ៉ាន់ ណាត ត្រូវបាន ឌុច កត់ត្រានៅក្នុងបញ្ជីឈ្មោះអ្នកទោស ។ អ្នកទោសទាំងអស់ដែលមានឈ្មោះនៅក្នុងបញ្ជីត្រូវបានសម្លាប់ចោល ប៉ុន្តែឈ្មោះរបស់ វ៉ាន់ ណាត ត្រូវបានឈូតចោលដោយមានការសរសេរជំនួសមួយដែលថា “ទុកដើម្បីប្រើប្រាស់” ។

## ឌុច ស្ថិតនៅចំកណ្តាលបរិវេណមន្ទីរស-២១ជារៀងរាល់ថ្ងៃ

សម្រាប់ថ្នាក់ក្រោមនៅមន្ទីរស-២១ដែលបានប្រាស្រ័យទាក់ទងជាមួយ ឌុច ដូចជាអ្នកយាមគុក អ្នកទោសនៅក្នុងរោងជាងរួមទាំង វ៉ាន់ ណាត ផង ពិតជាមានឱកាសឃើញនិងដឹងពីដំណើរប្រតិបត្តិការរបស់មន្ទីរស-២១ ។ វាពិតជា“កម្រ”ណាស់ដែលថា ឌុច មិនមកធ្វើការពិនិត្យដំណើរការវិវត្តន៍ទៅមុខនៅក្នុងរោងជាង ។ វ៉ាន់ ណាត បានគូសបញ្ជាក់ថា រោងជាងនោះគឺស្ថិតនៅចំកណ្តាលបរិវេណមន្ទីរស-២១ ដែលហ៊ុំព័ទ្ធទៅដោយសម្លេងស្រែកថ្ងូររបស់អ្នកទោស ។

វ៉ាន់ ណាត មិនដែលត្រូវស្ទួរចម្លើយ ឬទទួលទារុណកម្មនៅមន្ទីរស-២១ឡើយ ប៉ុន្តែរូបគំនូរ និងការគូសវាស់ជាច្រើនរបស់គាត់ បង្ហាញពីការយល់ដឹងពីហេតុការណ៍ដែលបានកើតឡើងនៅមន្ទីរស-២១ ។ លោកប្រធានចៅក្រម និល ណុន បានលើកបង្ហាញពីរូបភាពរបស់ វ៉ាន់ ណាត មួយចំនួនដែលឆ្លុះបញ្ចាំងពីការរំលោភបំពានផ្លូវភេទ ការឆក់ខ្សែភ្លើង ការប្រមុជទឹកជាច្រើនបែប ការអារ-កសម្លាប់ ការដកក្រចក និងរូបភាពអ្នកយាមគុកបំបែកកូនពីម្តាយ ។ រូបភាពមួយដែលបង្ហាញពីបុរសម្នាក់ត្រូវភ្ជួរ-កពីរបងឈើដ៏ខ្ពស់មួយ គឺពិតជាមានលក្ខណៈគួរឲ្យចាប់អារម្មណ៍ ពីព្រោះ វ៉ាន់ ណាត បានឃើញ

ហេតុការណ៍ធ្វើទារុណកម្មរបស់អ្នកទោសម្នាក់នេះដែលអះអាងថា ខ្លួនគឺជាជាងចម្លាក់ដ៏ពូកែនោះដោយផ្ទាល់ ប៉ុន្តែ ឌុច បានអះអាងថា រឿងនេះមិនពិតទេ។ មានម្តងនោះ វ៉ាន់ ណាត បានឃើញ ឌុច ទាត់អ្នកទោសម្នាក់ ប៉ុន្តែគាត់មិនបានឃើញ ឌុច ធ្វើទារុណកម្មលើអ្នកទោស ឬបញ្ជាឲ្យធ្វើទារុណកម្មឡើយ ។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ វ៉ាន់ ណាត ត្រូវបានខ្មែរក្រហមភ្នងការកាំភ្លើងបញ្ជាឲ្យរត់ភៀសខ្លួនពីមន្ទីរស-២១ជាមួយនឹងអ្នកទោសដប់បីនាក់ដែលធ្វើការក្នុងរោងជាង និងអ្នកយាមគុកជាច្រើននាក់ទៀត ។ គាត់ជឿថាមានអ្នកទោសជាច្រើននាក់ទៀតដែលនៅតែជាប់ឃុំឃាំងនៅមន្ទីរស-២១ ក្រោយពីការចាកចេញរបស់គាត់ទៅ ។ ប៉ុន្មានថ្ងៃក្រោយមក គាត់បានវិលត្រឡប់មកកាន់មន្ទីរស-២១វិញជាមួយនឹងអ្នកទោសបីនាក់ផ្សេងទៀត ដើម្បីមកយកសម្លៀកបំពាក់ខ្លះៗ ។ ប៉ុន្តែគាត់មិនអាចចូលទៅក្នុងបរិវេណមន្ទីរស-២១ឡើយដោយសារតែក្លិនសាកសពស្អុយរលួយ ។

សរុបសេចក្តីមក សក្ខីកម្មរបស់ វ៉ាន់ ណាត បានគូសបញ្ជាក់ហេតុការណ៍ជាច្រើនទាក់ទិននឹងស្ថានភាព និងដំណើរប្រតិបត្តិការរបស់មន្ទីរស-២១ ។ បើនិយាយពីទម្រង់បែបបទនៃការធ្វើទារុណកម្ម សក្ខីកម្មរបស់គាត់មានលក្ខណៈផ្ទុយពី ឌុច ដែលអះអាងថា ការធ្វើទារុណកម្មបួនប្រភេទនេះត្រូវបានទទួលស្គាល់ និងអនុវត្តជាញឹកញាប់ ។ វ៉ាន់ ណាត បានបញ្ជាក់ថា ឌុច ស្ថិតនៅចំកណ្តាលមន្ទីរស-២១ជារៀងរាល់ថ្ងៃ ។ សំខាន់ជាងនេះ ទោះបីជានៅក្នុងបន្ទប់ហាមឃាត់ក៏ដោយ វ៉ាន់ ណាត បានឮសម្លេងស្រែកថ្ងូរ យល់ដឹងពីដំណើរប្រតិបត្តិការ និងឃើញការធ្វើទារុណកម្មដែរ ។ សក្ខីកម្មនេះបានធ្វើការប្រឆាំងជាមួយនឹងការបញ្ជាក់ដ៏សំខាន់មួយរបស់ ឌុច ដែលថា គាត់គ្រប់គ្រងមន្ទីរស-២១ពីចម្ងាយតែប៉ុណ្ណោះ និងទទួលដឹងឮពីដំណើរប្រតិបត្តិការប្រចាំថ្ងៃតិចតួចបំផុត ។

## លទ្ធផលនៃការឃុំឃាំង : «វាមិនអាចបំភ្លេចបានទេ»

វ៉ាន់ ណាត បានឆ្លើយតបនឹងសំណួរជាច្រើនស្តីពីជីវិតក្រោយពីការជាប់ឃុំឃាំងនៅមន្ទីរស-២១ ។ គាត់បានរៀបរាប់ពីបទពិសោធន៍ដែលនៅតែលោងបន្លាច និងមិនបានអាចបំភ្លេចបានរបស់គាត់ ។ នៅពេលដែលត្រូវសួរថាហេតុអ្វីបានជាគាត់គូរទិដ្ឋភាពមន្ទីរស-២១ សរសេរសៀវភៅ និងចូលរួមក្នុងការផលិតជាឯកសារនោះ វ៉ាន់ ណាត បាននិយាយថាគាត់ចង់ឲ្យក្មេងជំនាន់ក្រោយដឹងពីទុក្ខវេទនារបស់

ប្រជាជនស្លូតត្រង់ដើម្បីចៀសវាងកុំឲ្យហេតុការណ៍អាក្រក់ស្រដៀងគ្នានេះកើតឡើងម្តងទៀត ។ នៅក្នុងការផ្លាស់ប្តូរអារម្មណ៍ដ៏រំជើបរំជួលនេះ លោកចៅក្រម ហ្សង់ម៉ាក ឡាវែន បានស្នើសុំឲ្យ វ៉ាន់ ណាត រៀបរាប់ពីក្តីសង្ឃឹមរបស់លោកដែលមានទៅលើដំណើរការអង្គជំនុំជម្រះនេះ ។ វ៉ាន់ ណាត បានពន្យល់ថាគាត់ចង់ឃើញតែភាពយុត្តិធម៌មួយមុខគត់ ។ គាត់បានបន្ថែមទៀតថា «ខ្ញុំមិនដែលនឹកស្មានថាខ្ញុំអាចមកអង្គុយនៅក្នុងបន្ទប់សវនាការក្នុងថ្ងៃនេះទេ ។ នេះគឺជាអត្ថប្រយោជន៍ និងកត្តិយសរបស់ខ្ញុំ ។ ខ្ញុំមិនចង់បានអ្វីលើសពីនេះនោះទេ» ។

មេធាវីការពារក្តីបានស្នើឲ្យជម្រើស វ៉ាន់ ណាត ក្នុងការមិនធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីទាំងនេះដោយគ្រាន់តែចូលរួមធ្វើជាសាក្សីវិញ ។ វ៉ាន់ ណាត បាននិយាយថា ការព្រួយបារម្ភចម្បងរបស់គាត់គឺបញ្ហាសុខភាព ហើយគាត់មិនគិតថាគាត់អាចចូលរួមក្នុងដំណើរការរបស់អង្គជំនុំជម្រះបានញឹកញាប់ទេ ។ បន្ថែមលើនេះ គាត់មិនមានបំណងទាមទារ សំណងថ្លៃខូចខាតអ្វីឡើយ ។ គាត់យល់ថាតុលាការនេះ គឺធ្វើឡើងសម្រាប់ប្រជាជនខ្មែរគ្រប់រូប ។ មេធាវីការពារក្តីបានបន្តភារៈកិច្ចដោយសួរសំណួរថាតើការបង្ហាញពីភាពសោកស្តាយ និងការទទួលស្គាល់ឧក្រិដ្ឋកម្មជាច្រើនរបស់ ឌុច អាចជួយឲ្យ វ៉ាន់ ណាត ជឿថាយុត្តិធម៌សម្រេចបានមួយផ្នែកហើយដែរឬទេ ។ រ៉ូបឺត ពើទីត សហព្រះរាជអាជ្ញាអន្តរជាតិបានជំទាស់នឹងសំណួរនេះ ហើយចៅក្រមអង្គជំនុំជម្រះយល់ស្របនឹងការជំទាស់នេះដោយអះអាងថា សំណួរនេះមានលក្ខណៈសមហេតុផលក្នុងការពិភាក្សាដេញដោលជាងការសួរសំណួរសាក្សី ។

## ភាពអាក់អន់ស្រពន់ចិត្តនឹងការកំណត់ពេលវេលា

ដូចដែលបានប្រកាសកាលពីសប្តាហ៍មុន នាពេលនេះចៅក្រមកំពុងតែអនុវត្តការកំណត់ពេលវេលាដ៏តឹងរឹង សម្រាប់ការសួរសំណួរសាក្សី ដើម្បីធ្វើយ៉ាងណាឲ្យអង្គជំនុំជម្រះដំណើរការទៅមុខបានលឿន ។ យ៉ាងណាមិញ ពេលវេលាដែលនៅសេសសល់ជារៀងរាល់ថ្ងៃមិនបានសម្រេចជាលទ្ធផលទៅមុខនោះទេ ។ ពេលវេលានៅក្នុងបន្ទប់សវនាការត្រូវបានប្រើប្រាស់កាន់តែមានប្រសិទ្ធិភាពជាងមុន ប៉ុន្តែអង្គជំនុំជម្រះមិនដំណើរការលឿនជាងមុខទាំងស្រុងទេ ។ ថ្ងៃនេះក្រោយពីចៅក្រមសួរសំណួរអស់រយៈពេលពីរម៉ោងមកការផ្តល់ពេលវេលាដែលនៅសល់គឺមានដូចតទៅ : សាមសិបនាទីសម្រាប់ព្រះរាជអាជ្ញា សែសិបនាទីសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងសែសិបនាទីទៀតសម្រាប់មេធាវីការពារក្តី ។

មុននឹងចាប់ផ្តើមសួរសំណួរ ស៊ីលឃី ស្ទូតហ្សិនស្កី មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការកត់សម្គាល់ពីពេលវេលាដែលផ្តល់ឲ្យនាពេលមុន ហើយបានស្នើសុំឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តីទទួលថិរវេលាបន្ថែមដើម្បីសួរសំណួរសាក្សីដ៏សំខាន់រូបនេះ ។ លោកស្រីបានកត់សម្គាល់ថា ខណៈពេលដែលដំណើរការនីតិវិធីកាលពីសប្តាហ៍មុនបានបញ្ចប់ទៅ ពេលវេលាបន្ថែមមិនត្រូវបានយកមកប្រើប្រាស់ឡើយ ។ បន្ទាប់ពីការផ្អាកដើម្បីពិភាក្សាមកលោកប្រធានចៅក្រមបានប្រកាសថា ការកំណត់ថិរវេលាត្រូវតែអនុវត្តឲ្យបានម៉ឺងម៉ាត់បំផុត ។ លោកប្រធាននិយាយថា ការពន្យាពេលជាច្រើនលើកបានកើតឡើងដោយសារតែការសួរសំណួរវែងៗ ។ ហេតុដូច្នេះអង្គជំនុំជម្រះត្រូវតែបន្តទៅមុខឲ្យបានលឿនដើម្បីយុត្តិធម៌ និងបំពេញទៅតាមតម្រូវការរបស់សាធារណជននិង«មជ្ឈដ្ឋានអន្តរជាតិ» ។

បន្ទាប់ពីការសួរសំណួរសន្និដ្ឋានបញ្ចប់របស់មេធាវីការពារក្តី ស្ទូតហ្សិនស្កី បានជំនះសួរសំណួររបស់មេធាវីការពារក្តីបន្ថែមទៀត ។ លោកស្រីបានស្នើសុំឲ្យចៅក្រមអនុញ្ញាតឲ្យលោកស្រីសួរសំណួរបន្តទៀតទាក់ទិននឹងហេតុការណ៍មួយដែលថាសាក្សីបានឃើញ ឌុច ទាត់អ្នកទោសម្នាក់ ។ ក្រោយមកលោកស្រីក៏បានប្តូរគំនិតដោយស្នើសុំឲ្យចៅក្រមសួរសាក្សីពីហេតុការណ៍សំខាន់មួយនេះ ។ ប៉ុន្តែចៅក្រម បានបដិសេធនឹងសំណើររបស់លោកស្រីដោយគ្មានភាពស្ទាក់ស្ទើរឡើយ ។

## សេចក្តីសម្រេចរបស់ចៅក្រម ៖ ការលុបចោលសាក្សី និងការប្រព្រឹត្តខុសក្រិដ្ឋកម្មរួម

ដោយរៀបចំដើម្បីធ្វើឲ្យអង្គជំនុំជម្រះដំណើរការទៅមុខកាន់តែលឿននោះ ចៅក្រមបានប្រកាសពីសេចក្តីសម្រេចរបស់ខ្លួនក្នុងការលុបចោលឈ្មោះសាក្សីពីបញ្ជីសាក្សីដែលមានលេខសម្គាល់ ដើម្បីការពារសុវត្ថិភាពផ្ទាល់សាក្សី ។ ចៅក្រមបានលើកហេតុផលថា សាក្សីទាំងនេះអាចនឹងផ្តល់«សក្ខីកម្មស្រដៀងគ្នា»នឹងសាក្សីផ្សេងទៀត ។ នាពេលខាងមុខ ចៅក្រមនឹងពិនិត្យមើលសេចក្តីអធិប្បាយរៀបរាប់របស់សាក្សីទាំងនោះក្នុងអំឡុងពេលដំណើរការស៊ើបអង្កេតសារឡើងវិញម្តងទៀត ។ ចៅក្រមបានបដិសេធមិនរក្សាទុកនូវ«បញ្ជីឈ្មោះសាក្សីបម្រុង»ឡើយ ដូច្នេះនេះគឺជាសេចក្តីសម្រេចចុងក្រោយបង្អស់ ។

ជាមួយគ្នានេះ ចៅក្រមក៏បានជម្រាបថាចៅក្រមនឹងសម្រេចថាតើគួរតែដាក់ការប្រព្រឹត្តខុសក្រិដ្ឋកម្មរួមធ្វើជាមធ្យោបាយកំណត់ភាពទទួលខុសត្រូវលើឧក្រិដ្ឋកម្មឬយ៉ាងណា ខណៈដែលចៅក្រមធ្វើសេចក្តីសម្រេច

លើកំណត់សម្គាល់ចម្បងទៅលើរឿងក្តីរបស់ ឌុច ។ នៅក្នុងការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញ ដោលកាលពីថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ ព្រះរាជអាជ្ញាបានស្នើថាការប្រព្រឹត្តឧក្រិដ្ឋកម្មរួមទាំងបីប្រភេទត្រូវតែយកមកពិចារណាដោយចៅក្រមទាក់ទិននឹងរឿងក្តីនេះ ។